**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីណែនាំ

## សូមស្វាគមន៍មកកាន់ "ពិព័រណ៍ពាណិជ្ជកម្មទីផ្សារអាហារ កម្ពុជា ២០២៦ "

ដើម្បីឱ្យកម្មវិធីប្រព្រឹត្តទៅដោយរលូន សុវត្ថិភាព និងបន្សល់ទុកនូវបទពិសោធន៍ដ៏ល្អសម្រាប់ភ្ញៀវទាំងអស់ សូមមេត្តាចូលរួមអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

1. **គោរពសណ្តាប់ធ្នាប់ និងការណែនាំ**
- សូមគោរពតាមការណែនាំរបស់គណៈកម្មការរៀបចំ និងបុគ្គលិកប្រចាំកម្មវិធី។
- សូមរក្សាសណ្តាប់ធ្នាប់ និងកុំប្រជ្រៀតគ្នានៅកន្លែងមានមនុស្សច្រើន។

2. **ថែរក្សាអនាម័យ**
- សូមបោះសំរាមចូលធុងសំរាមដែលបានរៀបចំ។
- សូមរក្សាបរិស្ថានឱ្យស្អាត ដើម្បីផ្តល់ផាសុកភាពដល់ភ្ញៀវទាំងអស់។

3. **ថែរក្សាទ្រព្យសម្បត្តិផ្ទាល់ខ្លួន**
- សូមយកចិត្តទុកដាក់ចំពោះទូរស័ព្ទ កាបូប និងសម្ភារៈមានតម្លៃ។
- គណៈកម្មការមិនទទួលខុសត្រូវចំពោះការបាត់បង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនឡើយ។

4. **គោរពអ្នកតាំងពិព័រណ៍**
- សូមកុំប៉ះពាល់ ឬប្រើប្រាស់ផលិតផលដោយគ្មានការអនុញ្ញាតពីម្ចាស់ស្តង់។
- សូមគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់អ្នកចូលរួមទាំងអស់។

5. **រក្សាសុវត្ថិភាព**
- សូមកុំរត់ ឬរុញច្រានគ្នា។
- សូមរក្សាផ្លូវដើរ និងច្រកចេញបន្ទាន់ឱ្យនៅទំនេរ។
- ក្នុងករណីមានអាសន្ន សូមអនុវត្តតាមការណែនាំរបស់ក្រុមសន្តិសុខជាបន្ទាន់។

6. **ការថតរូប និងវីដេអូ**
- ភ្ញៀវអាចថតរូប និងវីដេអូសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។
- សម្រាប់ការផ្សាយពាណិជ្ជកម្ម ឬការប្រើប្រាស់ពាណិជ្ជកម្មផ្សេងៗ សូមស្នើសុំការអនុញ្ញាតពីគណៈកម្មការជាមុន។

7. **គោរពវប្បធម៌ និងសុជីវធម៌**
- សូមប្រើពាក្យសម្តីសមរម្យ និងគោរពអ្នកដទៃ។
- មិនត្រូវបង្កការរំខាន ឬធ្វើសកម្មភាពដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

8. **ការហាមឃាត់**

សូមកុំ៖

- ដក់បារីនៅកន្លែងហាមឃាត់។
- នាំយកសារធាតុញៀន អាវុធ ឬវត្ថុគ្រោះថ្នាក់ចូលក្នុងកម្មវិធី។
- បង្កជម្លោះ ឬប្រើអំពើហិង្សា។
- លក់ផលិតផល ឬចែកផ្សាយសម្ភារៈផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត។

9. **ករណីបាត់របស់ ឬត្រូវការជំនួយ**

- សូមទាក់ទង តុព័ត៌មាន ( Information Desk ) ឬបុគ្គលិកប្រចាំកម្មវិធី។
- បុគ្គលិកនឹងជួយសម្របសម្រួល និងផ្តល់ព័ត៌មានជូនលោកអ្នកភ្លាមៗ។
- ទំនាក់ទំនងបន្ទាន់ កញ្ញា មាឃ សុគន្ធា 081 747 858 , លោក ឈុំ វណ្ណី 10 557 205

10. **មតិយោបល់ និងការវាយតម្លៃ**

- សូមចំណាយពេលបំពេញ Feedback Form តាម QR Code ឬនៅតុព័ត៌មាន។
- មតិយោបល់របស់លោកអ្នក គឺជាកម្លាំងជំរុញដ៏មានតម្លៃសម្រាប់ការរៀបចំកម្មវិធីនាពេលអនាគត។

<u>**សារពីគណៈកម្មការរៀបចំ**</u>

សូមអរគុណចំពោះការចូលរួម និងការគោរពតាមសេចក្តីណែនាំ។ ការចូលរួមរបស់លោកអ្នក គឺជាចំណែកមួយក្នុងការជួយបង្កើតបរិយាកាសពិព័រណ៍ដែលមានសុវត្ថិភាព ស្អាត មានសណ្តាប់ធ្នាប់ និងប្រកបដោយភាពរីករាយសម្រាប់អ្នកទាំងអស់គ្នា។

សូមជូនពរឱ្យលោកអ្នកទទួលបានបទពិសោធន៍ដ៏ល្អ និងរីករាយជាមួយ "**ពិព័រណ៍ពាណិជ្ជកម្មទីផ្សារអាហារកម្ពុជា ២០២៦** "

ថ្ងៃសុក្រ ៣កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០២៦